# សន្និបាតបូកសរុបលទ្ធផលការងារ
# ប្រចាំឆ្នាំ២០២៤ និង ទិសដៅអនុវត្តឆ្នាំ២០២៥

## ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរទន្លេសាប

## លទ្ធផលការងារផែនការ និងសហប្រតិបត្តិការប្រចាំ២០២៤ និង ទិសដៅអនុវត្តឆ្នាំ២០២៥

នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ



## ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក(២០២៤-២០២៨) និងផែនការសកម្មភាពរបស់ក្រសួងធនធានទឹកនិងឧតុនិយម នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមចំណែកដល់លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ តាមរយៈការអនុវត្តភារៈកិច្ចរបស់ខ្លួនដូចខាងក្រោម៖

### ក.ការងារផែនការ

- បន្តសហការជាមួយក្រសួងផែនការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដោយផ្តល់ធាតុចូលលើការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម រយៈពេល ៥ឆ្នាំ (២០២៤-២០២៨) របស់ក្រសួង
- សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបញ្ចូលទិន្នន័យ សូចនាករ ចូលរួមទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨) និងយុទ្ធសាស្ត្របញ្ចកោណដំណាក់ទី១ របស់រាជរដ្ឋាភិបាល
- រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ (PIP) ៣ឆ្នាំរំកិល របស់ក្រសួងជារៀងរាល់ឆ្នាំ ដើម្បីផ្ញើទៅជូនក្រសួងផែនការ

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ក.ការងារផែនការ (ត)

- ចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃរាល់ការអនុវត្តគម្រោងប្រើប្រាស់ថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ (M&E) នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម តាមបណ្តារាជធានី-ខេត្ត
- សហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាតាមកម្មវិធីប្រចាំឆ្នាំនីមួយៗ
- បូកសរុបរបាយការណ៍ប្រចាំខែ នីមួយៗ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ របស់ក្រសួង ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ដឹកនាំក្នុងក្រសួង ព្រមទាំងបណ្តានាយកដ្ឋានក្រោមឱវាទ
- ធ្វើការបូកសរុបរបាយការណ៍តាមបណ្តានាយកដ្ឋានទាំង១២ និងតាមបណ្តារាជធានី-ខេត្តទាំង២៥.



# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ខ. ការងារស្ថិតិ

- បន្តរៀបចំចងក្រងបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួងសម្រាប់លើកផែនការអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមរយៈពេលខ្លី មធ្យម និងវែងលើគ្រប់ផ្នែកទាំងអស់
- ចុះប្រមូល និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រព័ន្ធធារាសាស្ត្រចំនួន ១៨ខេត្ត បានចំនួន ២៦០ប្រព័ន្ធ
- ចុះពង្រឹងសមត្ថភាពមន្ត្រីមន្ទីរលើជំនាញការគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិ និងជំនាញការរៀបចំផែនទីតាមកម្មវិធី GIS បានចំនួន ៨ខេត្ត មន្ត្រីសរុបចំនួន ១៦៧ រូប ក្នុងនោះស្ត្រីចំនួន ២១រូប

## គ. ការងារវិមជ្ឈការ និងសហវិមជ្ឈការ

- បន្តលើកកម្ពស់ការងារផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចុះពិនិត្យតាមដានមុខងារដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ ក្នុងខេត្តចំនួន ៣ខេត្ត រួមមាន ខេត្តកណ្ដាល កំពង់ធំ និងខេត្តសៀមរាប
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើមុខងារវិស័យធនធានទឹក និងឧតុនិយម ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តកំពង់ធំ សរុបសិក្ខាកាមចូលរួមចំនួន ១៩៥នាក់ (ស្ត្រី២១នាក់)
- រៀបចំកិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យមុខងារដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ លើកទិសដៅអនុវត្តបន្ត និងរៀបចំជារបាយការណ៍ បានចំនួន៤លើក

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ក.កិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន

ក្រសួងធនធានទឹក និងឧតុនិយមបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេស ដើម្បីធានាបាននូវការអភិវឌ្ឍ និងកាគ្រប់គ្រងធនធានទឹក ប្រកបដោយប្រសិទ្ធភាព និងចីរភាព៖

- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈក្រុមការងារត្រី-វិស័យ សម្រាប់ការសម្របសម្រួលការអនុវត្តកម្មវិធីនយោបាយ និងសកម្មភាពដែលពាក់ព័ន្ធនឹង សហគមន៍កសិកម្មទំនើបសហគមន៍កសិករប្រើប្រាស់ទឹក និងភូមិគំរូ
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម តាមរយៈក្រុមការងារបច្ចេកទេសចម្រុះកសិកម្ម និងទឹក
- សហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងអភិវឌ្ឍន៍ ដើម្បីដោះស្រាយ និងអន្តរាគមន៍លើបញ្ហាប្រភពទឹកសម្រាប់ផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋ

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ក.កិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន (ត)

- សហការជាមួយក្រសួងបរិស្ថាន ដោយធ្វើជាជនបង្គោលនៃ UN Water សម្រាប់រៀបចំ SDG 6.5.1 : IWRM ដែលត្រូវការវាយតម្លៃរយៈពេល ២ឆ្នាំម្តង និងជាសមាជិកក្រុមការងារ បច្ចេកទេសប្រែប្រួលអាកាសធាតុ និងក្រុមការងារបច្ចេកទេសសម្របសម្រួលការគ្រប់គ្រងបឋបនីយដីវម៉ណ្ឌលបឹងទន្លេស
- ចូលរួមសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈគណៈកម្មការវិនិយោគកម្ពុជា (ច្រកចេញ ចូលតែមួយ) ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណើវិនិយោគនានា
- ចូលរួមសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការប្រមូលទិន្នន័យ នឹងការសិក្សាគម្រោងអភិវឌ្ឍន៍ផ្លូវនាវាចរណ៍ ហ្វូណនតេជោ
- ចូលរួមសហការជាមួយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការគណៈកម្មការទន្លេមេគង្គក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាព
- ចូលរួមសហការជាមួយអាជ្ញាធរទន្លេសាបក្នុងការកំណត់ព្រំប្រទល់ និងបោះបង្គោលតំបន់ទាំងបីនៃអាងបឹងទន្លេសាប




















## ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ៥. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

### ៥.១. ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ និងការងារអាស៊ាន

- បង្កើតកម្មវិធីសហប្រតិបត្តិការអន្តរជាតិ និងបណ្ដាប្រទេសជាសមាជិកអាស៊ានលើវិស័យអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម
- បន្តការងារសម្របសម្រួលជំនួយពីបរទេស និងដៃគូអភិវឌ្ឍន៍លើផ្នែកបច្ចេកវិទ្យាការប្រែប្រួលអាកាសធាតុ
- រៀបចំឯកសារកិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងធនធានទឹក និងឧតុនិយម ជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍
- រៀបចំផែនការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងធ្វើរបាយការណ៍លើការអនុវត្តកិច្ចសហប្រតិបត្តិការនេះជូនថ្នាក់ដឹកនាំ

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ៥. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

### ៥.២.កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួនដែលបាន និងកំពុងបន្តផ្តល់ហិរញ្ញប្បទាន ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស រួមមាន៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារបារាំង សម្រាប់ការអភិវឌ្ឍ (AFD) ធនាគារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ធនាគារពិភពលោក (WB) ប្រទេសជប៉ុន ប្រទេសបារាំង ប្រទេសឥណ្ឌា ប្រទេសកូរ៉េ និងសាធារណរដ្ឋប្រជាមានិតចិន។ល។





# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ២. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

### ២.២.កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ (ត)

ជំនួយជាហិរញ្ញប្បទាន និងជំនួយឥតសំណងផ្តល់ដោយដៃគូអភិវឌ្ឍន៍
សម្រាប់គម្រោងដែលកំពុងអនុវត្តន៍ ឆ្នាំ២០២៤ (លានដុល្លា)




- គិតត្រឹមឆ្នាំ២០២៤ មាន**ដៃគូអភិវឌ្ឍន៍ចំនួន ៧៖** ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ធនាគារវិនិយោគអឺរ៉ុប (EIB) សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន (JICA) ប្រទេសកូរ៉េ (KOICA) និងធនាគារពិភពលោក (WB)
- **គាំទ្រថវិកាសរុប**ចំនួនប្រមាណ **១.២៨៨,១៨ លានដុល្លា** សម្រាប់ការអនុវត្តគម្រោងចំនួន ១៥
- ជួយបង្កើន**លទ្ធភាពស្រោចស្រពលើផ្ទៃ**ដីសរុបប្រមាណ **៤៦៧,៩៥៤ ហិកតា។**

# ខ.២.កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ (ត)

| ល.រ | ឈ្មោះគម្រោង | ដៃគូអភិវឌ្ឍន៍/ប្រទេស | រយៈពេលនៃគម្រោង | ភាគរយនៃការបញ្ចប់ (%) |
|---|---|---|---|---|
| ១ | គម្រោងខ្សែច្រវាក់ផលិតកម្មភាតរះបរិស្ថាន | ADB | 2020-2026 | ៣០ |
| ២ | គម្រោងកែសម្រួលប្រព័ន្ធធារាសាស្ត្រ | ADB | 2019-2027 | ៧២ |
| ៣ | គម្រោងកែសម្រួលប្រព័ន្ធធារាសាស្ត្រ | EIB | 2023-2025 | ១៥ |
| ៤ | កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរកសិ-អេកូឡូស៊ីសម្រាប់កម្ពុជា (ដំណាក់កាលទី១) | AFD | 2019-2025 | ៧៥ |
| ៥ | គម្រោងស្វាយចេក | AFD | 2024-2027 | ១០ |
| ៦ | គម្រោងប្រព័ន្ធធារាសាស្ត្រស្ទឹងព្រែកត្នោត និងគ្រប់គ្រងទឹកជំនន់ | China | 2023-2025 | ១០០ |
| ៧ | គម្រោងអភិវឌ្ឍន៍អាងស្តុកទឹកដងកាំបិត | China | 2023-2025 | ៤៦ |
| ៨ | គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់ | India | 2018-2024 | ៣០ |
| ៩ | គម្រោងការប្រើប្រាស់ធនធានទឹកអាងទន្លេ | Japan | 2022-2025 | ១០០ |
| ១០ | គម្រោងអភិវឌ្ឍន៍ឯកសាររចនាស្តង់ដារជាតិ សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងការផ្គូរទឹក។ | Japan | 2022-2026 | ៦០ |
| ១១ | គម្រោងស្តារ និងកែលម្អប្រព័ន្ធធារាសាស្ត្រ និងប្រឡាយនៅភាគនិរតី រាជធានីភ្នំពេញ | Japan | 2024-2026 | ៣២ |
| ១២ | គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងកាត់បន្ថយទឹកជំនន់ | Korea | 2017-2026 | ៥៩ |
| ១២ | គម្រោងកាត់បន្ថយទឹកជំនន់ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្របរិល | Korea | 2024-2029 | ១២ |
| ១៤ | គម្រោងអភិវឌ្ឍន៍ទំនប់ជូនទ្រី | Korea | 2021-2025 | ៩១ |
| ១៤ | គម្រោងកែលម្អសន្តិសុខទឹកកម្ពុជា | WB | 2024-2030 | ១០ |
| ១៦ | ការបង្វែរទឹកជំនន់ពីរាជធានីភ្នំពេញ | RGC | 2023-2026 | ៩៧ |
| ១៧ | គម្រោងអភិវឌ្ឍន៍សំណង់ស្នាក់ទឹកកំពង់គោ | RGC | 2024-2026 | ៣០ |

វឌ្ឍនភាពនៃការអនុវត្តបណ្តាគម្រោងដែលកំពុងដំណើរការ និងបញ្ចប់ក្នុងឆ្នាំ២០២៤ ដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ខ. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

### ខ.២.កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ (ត)

ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៤ **មានគម្រោងធំៗចំនួន៧ត្រូវបានបញ្ចប់** គម្រោងចំនួន**១៥កំពុងត្រូវបានអនុវត្តន៍** និង **គម្រោង៣២ដែលគ្រោងអនុវត្តន៍រហូតដល់ឆ្នាំ២០៣៤** ដោយប្រើប្រាស់ថវិកាជាហិរញ្ញប្បទាន និងជំនួយឥតសំណង របស់ដៃគូអភិវឌ្ឍន៍ ដោយក្នុងនោះមានដៃគូអភិវឌ្ឍន៍សំធំៗ ដូចជា៖ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ធនាគារវិនិ សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន (JICA) និងប្រទេសកូរ៉េ (KOICA)។



# ២. បញ្ហាប្រឈម

- ធនធានមនុស្ស និងមន្ត្រីដែលមានជំនាញច្បាស់លាស់ផ្នែកផែនការ ស្ថិតិ ភាសាអង់គ្លេស និងទំនាក់ទំនងអន្តរជាតិ នៅមានកំរិត
- កិច្ចសហការ ការចែករំលែក និងរំហូរព័ត៌មាន និងទិន្នន័យស្តីពីការអនុវត្តគម្រោងដៃគូនៅអភិវឌ្ឍន៍មានកំណត់
- គោលការណ៍ណែនាំមួយចំនួនដែលចាំបាច់ដែលគាំទ្រដល់កិច្ចដំណើរការ ប្រតិបត្តិការរដ្ឋបាល និងទំនាក់ទំនងអន្តរជាតិ មិនទាន់ត្រូវបានបង្កើត
- សម្ភារៈ និងបច្ចេកវិទ្យាគាំទ្រ នៅមានការខ្វះខាត
- ថវិកា និងចំនួនមន្ត្រីដែលមានសមត្ថភាពពុំទាន់ឆ្លើយតបនឹងទំហំការងារ និងតម្រូវការជាក់ស្តែង។








# ៣. សេចក្តីសន្និដ្ឋាន

- កិច្ចសហប្រតិបត្តិការកន្លងមក និងក្នុងឆ្នាំ២០២៤ រវាងក្រសួងធនធានទឹក និងឧតុនិយម ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដែលធ្វើការងារទាក់ទងនឹងវិស័យធនធានទឹកបាននាំមកនូវសមិទ្ធផល គួរឱ្យកត់សម្គាល់ក្នុងការចូលរួមចំណែកធានាសន្តិសុខទឹក និងការផ្គត់ផ្គង់ទឹកឱ្យបានសមរម្យសម្រាប់បម្រើដល់ការអភិវឌ្ឍគ្រប់វិស័យ។

- ដើម្បីធ្វើឱ្យសន្តិសុខទឹក និងការផ្គត់ផ្គង់ទឹកកាន់តែប្រសើរឡើង នាយកដ្ឋាននឹងបន្តខិតខំ ប្រឹងប្រែង និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគរជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញប្បទាន ដើម្បីធានាថាជំនួយទាំងនោះនឹងឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងអាទិភាពរបស់ក្រសួងក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០២៤-២០២៨ ។

- ជាសេចក្តីសន្និដ្ឋានរួម ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិបានសហការគ្នាក្នុងការបំពេញតួនាទី និងភារកិច្ចប្រកបដោយការខិតខំប្រឹងប្រែងទៅតាមសមត្ថភាពនិងធនធានដែលមាន និងទទួលបានលទ្ធផលគួរជាទីកត់សម្គាល់ ដោយមានការការណែនាំ និងការតម្រង់ទិសពីថ្នាក់ដឹកនាំ។

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥

នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិមានទិសដៅអនុវត្តឆ្នាំ២០២៥ ដូចខាងក្រោម៖

- សហការក្នុងការរៀបចំលទ្ធផល សមិទ្ធផល លើវិស័យធនធានទឹក និងឧតុនិយម ប្រចាំឆ្នាំ
- រៀបចំពង្រាងផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងវិស័យធនធានទឹក និងឧតុនិយមរយៈពេល ៥ឆ្នាំ (២០៤-២០២៨)
- បន្តរៀបចំកម្មវិធីវិនិយោគសាធារណៈ PIP ៣ឆ្នាំរំកិល ឲ្យបានល្អប្រសើរជាងមុន
- សហការរៀបចំផែនការយុទ្ធសាស្រ្តថវិកា
- ចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃរាល់ការអនុវត្តគម្រោងនៃការអនុវត្តផែនការ ទាំងថវិកាជាតិថវិកាដៃគូអភិវឌ្ឍន៍ដោយប្រមូលទិន្នន័យឲ្យបានគ្រប់គ្រាន់ ជាក់លាក់គ្រប់ជ្រុងជ្រោយយកមកប្រើប្រាស់បាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ឲ្យបានទាន់ពេលវេលា
- ចុះប្រមូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រព័ន្ធធារាសាស្រ្តចំនួន ៣០០ប្រព័ន្ធ
- ចុះបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពចំណេះដឹងលើជំនាញរៀបចំផែនទី ជូនមន្ត្រីមន្ទីររាជធានី-ខេត្តចំនួន ១០ខេត្ត/ឆ្នាំ

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

- រៀបចំចងក្រងរបាយការណ៍វឌ្ឍនៈភាព និងបញ្ចីកម្រងសំនួរបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ Database (បពបសក) ក្នុងការិយាល័យស្ថិតិ
- ចូលរួមធ្វើកម្មវិធីសហប្រតិបត្តិការអន្តរជាតិ និងបណ្តាប្រទេសអាស៊ានក្នុង និងក្រៅប្រទេសលើវិស័យអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម
- សម្របសម្រួលជំនួយពីបរទេស និងដៃគូអភិវឌ្ឍន៍លើផ្នែកបច្ចេកវិទ្យា ការប្រែប្រួលអាកាសធាតុ
- បញ្ជូនមន្ត្រីក្រោមឱវាទនាយកដ្ឋានចូលរួមកិច្ចសហប្រតិបត្តិការនៅតាមបណ្តាប្រទេសផ្តល់ជំនួញលើការអភិវឌ្ឍន៍វិស័យធនធានទឹក
- ពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលគ្រូបង្គោល(TOT) សិក្ខាសាលា វេទិកាយេនឌ័រ កិច្ចប្រជុំក្រុមការងារប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ ទស្សនកិច្ចសិក្សា និងផ្សព្វផ្សាយអនុសញ្ញាស៊ីដ (ចំនួន ៥វគ្គ) និងមានការចូលរួមពីមន្ត្រីគ្រប់លំដាប់ថ្នាក់ និងរាជធានី-ខេត្ត និងកម្រិតសកបទ
- ចុះសិក្សាស្រាវជ្រាវពីតួនាទី និងបញ្ហាយេនឌ័រ តាមសកបទ ចំនួន ១០ខេត្ត និងបញ្ចូលទិន្នន័យ
- លើកកម្ពស់ការងារផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វិស័យធនធានទឹកនិងចុះត្រួតពិនិត្យវាយតម្លៃលើអនុវត្តមុខងារដែលបានផ្ទេររួច។

# សូមអរគុណ

# THANK YOU

